# សេចក្តីថ្លែងការណ៍រួម
# ស្តីពីទស្សនកិច្ចផ្លូវការរបស់ឯកឧត្តម ខេ ភី សាម៉ា អូលី
# នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់
# នៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៣-១៥ ខែឧសភា ឆ្នាំ ២០១៩

----

១.	តាមការអញ្ជើញរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម ខេ ភី សាម៉ា អូលី** នាយករដ្ឋមន្ត្រីនៃប្រទេស**នេប៉ាល់** បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រ**កម្ពុជា** ពីថ្ងៃទី១៣ ដល់១៥ ខែឧសភា ឆ្នាំ២០១៩ អមដំណើរដោយលោកជំទាវ រ៉ាឌីកា សាក់យ៉ា ឯកឧត្តម ប្រាឌីប គូម៉ា ហ្គាវ៉ាលី រដ្ឋមន្ត្រីការបរទេស ទីប្រឹក្សានាយករដ្ឋមន្ត្រី សមាជិកសភា មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ព្រមទាំងគណៈប្រតិភូធុរកិច្ច។

២.	**ឯកឧត្តមនាយករដ្ឋមន្ត្រីនេប៉ាល់** និង**លោកជំទាវ** បានអញ្ជើញទៅដាក់កម្រងផ្កា នៅស្តូបវិមានឯករាជ្យ និងគោរពវិញ្ញាណក្ខន្ធវីរបុរស និងវីរនារីកម្ពុជា ដែលបានពលីក្នុងសង្គ្រាម និងបានអញ្ជើញទៅគោរពព្រះវិញ្ញាណក្ខន្ធ**អតីតព្រះមហាក្សត្រកម្ពុជា ព្រះករុណា ព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ព្រះវររាជបិតាកម្ពុជា។ **ឯកឧត្តមនាយករដ្ឋមន្ត្រីនេប៉ាល់** និង**លោកជំទាវ** ក៏បានអញ្ជើញទៅទស្សនាសារមន្ទីរជាតិ និងវត្តព្រះកែវមរកត ព្រមទាំងទស្សនាវិមានឈ្នះ-ឈ្នះ ដែលបង្ហាញដំណើលប្រវត្តិសាស្ត្រពីជោគជ័យនៃកិច្ចប្រឹងប្រែងរបស់កម្ពុជា ដើម្បីនាំមកនូវសន្តិភាពពេញលេញ ការផ្សះផ្សានិងការបង្រួបបង្រួមជាតិរបស់កម្ពុជា។

៣.	ក្នុងអំឡុងពេលទស្សនកិច្ច **ឯកឧត្តមនាយករដ្ឋមន្ត្រីនេប៉ាល់** បានជួបសម្តែងការគួរសមជាមួយ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងជាប្រមុខរដ្ឋស្តីទី និង **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។

៤.	**ឯកឧត្តមនាយករដ្ឋមន្ត្រីនេប៉ាល់** បានជួបពិភាក្សាទ្វេភាគីជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងបរិយាកាសប្រកបដោយមិត្តភាព និងការយោគយល់គ្នាទៅវិញទៅមក។ ដោយរំលឹកពីទស្សនកិច្ចលើកដំបូងនៅ**នេប៉ាល់** ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសម្តែងកិច្ចស្វាគមន៍ចំពោះទស្សនកិច្ចតបវិញរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រីនេប៉ាល់ ខេ ភី សាម៉ា អូលី** ថាជា "ទស្សនកិច្ចប្រវត្តិសាស្ត្រ" និងបានកត់សម្គាល់ថាទស្សនកិច្ចនេះនឹងធ្វើឲ្យទំនាក់ទំនងដ៏ល្អប្រសើរដែលមានស្រាប់រវាងប្រទេសជាមិត្តទាំងពីរឈានឡើងកាន់តែខ្ពស់ថែមទៀត។ **ឯកឧត្តមនាយករដ្ឋមន្ត្រី ខេ ភី សាម៉ា អូលី** បានចាត់ទុកកម្ពុជា ជាមិត្តដ៏ជិតស្និទ្ធរបស់**នេប៉ាល់** និងជាដៃគូដ៏សំខាន់មួយនៅក្នុងតំបន់។

៥.	**នាយករដ្ឋមន្ត្រីទាំងពីរ**បានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅស្តីពីការជម្រុញកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យជាច្រើន រួមមានពាណិជ្ជកម្ម និងការវិនិយោគ ទេសចរណ៍ វប្បធម៌ និងការអប់រំ ហើយបានផ្លាស់ប្តូរទស្សនៈគ្នាស្តីពីបញ្ហាតំបន់ និងអន្តរជាតិ ដែលមានផលប្រយោជន៍ទៅវិញទៅមក។ **នាយករដ្ឋមន្ត្រីទាំងពីរ** បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីពង្រឹងឲ្យកាន់តែស៊ីជម្រៅថែមទៀតនូវទំនាក់ទំនងមិត្តភាពរវាងកម្ពុជា និងនេប៉ាល់ ដែលមានឫសគល់យ៉ាងជ្រៅនៅក្នុងកេរ្តិ៍ដំណែលវប្បធម៌រួមនៃប្រទេសទាំងពីរ។

**នាយករដ្ឋមន្ត្រីទាំងពីរ** បានកត់សម្គាល់ដោយការពេញចិត្តផងដែរថា **កម្ពុជា** និង **នេប៉ាល់** បានអភិវឌ្ឍភាពជាដៃគូដ៏រឹងមាំដែលផ្តល់ប្រយោជន៍ទៅវិញទៅមកក្នុងកម្រិតទ្វេភាគី តំបន់ និងពហុភាគី ដើម្បីបុព្វហេតុសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសទាំងពីរ និងពិភពលោក។

៦. **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានកោតសរសើរយ៉ាងខ្លាំងចំពោះការផ្លាស់ប្តូរនយោបាយជាប្រវត្តិសាស្ត្ររបស់នេប៉ាល់ និងដំណើរការសន្តិភាពដោយនេប៉ាល់ខ្លួនឯង ព្រមទាំងស្ថិរភាពដែលកើតមានក្នុងប្រទេសនេប៉ាល់ ក្រោមការដឹកនាំរបស់**ឯកឧត្តមនាយករដ្ឋមន្ត្រី ខេ ភី សាម៉ា អូលី** ដែលបានអនុញ្ញាតឲ្យប្រទេសនេះផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ប្រកបដោយចីរភាព។ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានជូនពរសូមឲ្យនេប៉ាល់សម្រេចបានបំណងប្រាថ្នាជាតិ "នេប៉ាល់រុងរឿង នេប៉ាល់រីករាយ"។ **ឯកឧត្តមនាយករដ្ឋមន្ត្រី ខេ ភី សាម៉ា អូលី** ក៏បានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបន្តរក្សាបានដោយជោគជ័យនូវសន្តិភាព ស្ថិរភាព កំណើនសេដ្ឋកិច្ចដ៏ខ្ពស់ ឧស្សាហកម្មទេសចរណ៍រឹងមាំ និងភាពប្រសើរឡើងនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន**។

៧. នាយករដ្ឋមន្ត្រីទាំងពីរបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ជាទៀងទាត់ និងការពិគ្រោះយោបល់ ដែលនឹងកំណត់បាននូវវិធី និងមធ្យោបាយ ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ សំដៅនាំមកនូវផលប្រយោជន៍ទៅវិញទៅមកដល់ប្រជាជាតិទាំងពីរ។ ក្នុងគោលដៅនេះ ថ្នាក់ដឹកនាំទាំងពីរបានឯកភាពគ្នាថា គួរតែចាប់ផ្តើមឲ្យបានឆាប់បំផុតនូវដំណើរការនៃកិច្ចពិគ្រោះយោបល់រវាងក្រសួងការបរទេសទាំងពីរ ។

៨. ដោយទទួលស្គាល់ថាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងកម្ពុជា និងនេប៉ាល់នៅមានកង្វះខាតច្រើនដែលអាចជម្រុញឲ្យបានប្រសើរឡើង នាយករដ្ឋមន្ត្រីទាំងពីរបានឯកភាពប្រគល់ភារកិច្ចទៅស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ឲ្យធ្វើការរួមគ្នាដើម្បីបង្កើនការផ្លាស់ប្តូរពាណិជ្ជកម្មទ្វេភាគី ការវិនិយោគ និងទេសចរណ៍។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់ផ្នែកឯកជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងបានលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងសភាពាណិជ្ជកម្មកម្ពុជា និងនេប៉ាល់ ដើម្បីប្រើប្រាស់ឲ្យបានពេញលេញនូវសក្តានុពលសេដ្ឋកិច្ច និងកាលានុវត្តភាពធុរកិច្ចនៃប្រទេសទាំងពីរ។

៩. នាយករដ្ឋមន្ត្រីទាំងពីរបានធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីពាណិជ្ជកម្ម និងវិនិយោគរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនេប៉ាល់ និងអនុស្សរណៈនៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មនេប៉ាល់។ នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នានេះ និងបានសម្តែងនូវសុទិដ្ឋិនិយមថាជាមួយនឹងការចុះហត្ថលេខាលើឯកសារទាំងពីរនេះ សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ នឹងកាន់តែមានការរីកចម្រើនឡើង នាពេលអនាគតដ៏ខ្លីខាងមុខ។

១០. ដោយរំលឹកពីការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការឯកភាពរបស់ភាគីទាំងពីរ ដើម្បីចុះហត្ថលេខាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្នុងអំឡុងពេលទស្សនកិច្ចរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅនេប៉ាល់** កាលពីខែវិច្ឆិកា ឆ្នាំ២០១៨ នាយករដ្ឋមន្ត្រីទាំងពីរបានណែនាំអាជ្ញាធរអាកាសចរស៊ីវិលរៀងៗខ្លួន ឲ្យពន្លឿនកិច្ចពិភាក្សាស្តីពីការចុះហត្ថលេខា និងអនុវត្តនូវកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។ នាយករដ្ឋមន្ត្រីទាំងពីរមានទស្សនៈរួមគ្នាថា ការតភ្ជាប់ផ្លូវ

អាកាសដោយត្រង់ គឺជាតម្រូវការចាំបាច់ដើម្បីសម្រួលការផ្លាស់ប្តូរគ្នាផ្នែកធុរកិច្ច និងទេសចរណ៍រវាងប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពជម្រុញស្ថាប័នពាក់ព័ន្ធទាំងអស់នៃប្រទេសទាំងពីរឲ្យធ្វើការរួមគ្នាជិតស្និទ ដូចជាតាមរយៈសកម្មភាពផ្សព្វផ្សាយរួមគ្នា និងការប្រើប្រាស់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ដ៏សម្បូរបែបនៃប្រទេសទាំងពីរ ដើម្បីបង្កើនការផ្លាស់ប្តូរទេសចរណ៍។

១១. ថ្នាក់ដឹកនាំទាំងពីរបានកត់សម្គាល់ដោយពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការវប្បធម៌ ដែលកំពុងតែមានការរីកចម្រើនឡើង បន្ទាប់ពីការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌រវាងប្រទេសទាំងពីរ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការជឿជាក់ថា ការអនុវត្តអនុស្សរណៈនេះឲ្យមានប្រសិទ្ធភាព មិនត្រឹមតែជម្រុញការយោគយល់គ្នាទៅវិញទៅមក និងមិត្តភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកលើកកម្ពស់ឧស្សាហកម្មទេសចរណ៍នៃប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពគ្នា លើកទឹកចិត្តការប្រាស្រ័យទាក់ទងគ្នារវាងប្រជាជន និងប្រជាជនតាមរយៈកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំផងដែរ។

១២. នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការពេញចិត្តចំពោះកម្រិតនៃកិច្ចសហប្រតិបត្តិការពហុភាគីដែលកំពុងតែរីកចម្រើនរវាងប្រទេសកម្ពុជា និងនេប៉ាល់ និងបានឯកភាពថា តំណាងនៃប្រទេសទាំងពីរគួរតែសហការឲ្យបានជិតស្និទថែមទៀតលើវេទិកាតំបន់ និងអន្តរជាតិ រួមទាំងអង្គការសហប្រជាជាតិ ដើម្បីសន្តិភាព ស្ថិរភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងវិបុលភាពរួម។

១៣. ថ្នាក់ដឹកនាំទាំងពីរបានថ្លែងសុន្ទរកថារួមគ្នានៅក្នុងវេទិកាធុរកិច្ចកម្ពុជា-នេប៉ាល់ ហើយបានលើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរគ្នាផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ។

១៤. ឯកឧត្តមនាយករដ្ឋមន្ត្រី **ខេ ភី សាម៉ា អូលី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និងប្រជាជន**កម្ពុជា** ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅនិងបានផ្តល់បដិសណ្ឋារកិច្ច ជូនចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី លោកជំទាវ និងប្រតិភូអមដំណើរ ក្នុងអំឡុងពេលស្នាក់នៅទីក្រុងភ្នំពេញ។

១៥. ឯកឧត្តមនាយករដ្ឋមន្ត្រីនេប៉ាល់ បានអញ្ជើញ**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ទៅបំពេញទស្សនកិច្ចនៅនេប៉ាល់ តាមពេលវេលាសមស្របរបស់**សម្តេចតេជោ**។ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានទទួលយកការអញ្ជើញនេះ ដោយសេចក្តីរីករាយ និងបានថ្លែងអំណរគុណ**ឯកឧត្តមនាយករដ្ឋមន្ត្រី ខេ ភី សាម៉ា អូលី** ចំពោះការអញ្ជើញនេះ។ កាលបរិច្ឆេទនៃទស្សនកិច្ចនឹងត្រូវពិគ្រោះគ្នាតាមផ្លូវការទូត។

ថ្ងៃពុធ ១២កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩

---